**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍

## កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រយុទ្ធនឹងជំងឺអេដស៍

## ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

### ១-គោលបំណង

គោលបំណងនៃកិច្ចប្រជុំមាន បញ្ចប់ការពិនិត្យលើពង្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៥ និងការកែសម្រួលសេចក្តីសម្រេចនៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ និងពិនិត្យលើអនុសាសន៍នៃកិច្ចប្រជុំប្រចាំត្រីមាស។

តាមរយៈនៃកិច្ចប្រជុំ សមាជិកក្រុមការងារទាំងអស់រំពឹងថា នឹងបានរបាយការណ៍ និងការកែសម្រួលសេចក្តីសម្រេចនៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

### ២-កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន

កាលបរិច្ឆេទ: ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦

ទីកន្លែង : នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

វត្តមាន : អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ MHC, MHSS,SIT,RHAC,BC,PSK, PSC, FHI360,AHF,Khemara,and MEC.

### ៣-វិធីសាស្ត្រ : ពិភាក្សារួម

### ៤-លទ្ធផល

នៅថ្ងៃពុធ ទី១១ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំនូវកិច្ចប្រជុំប្រចាំខែរបស់ក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានសមាជិកចូលរួមប្រមាណ១៦នាក់ ក្រោមការដឹកនាំកិច្ចប្រជុំដោយ លោកវេជ្ជ. វ៉ឹង យ៉ាណាត ប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។ ជាកិច្ចចាប់ផ្តើម លោកប្រធានកិច្ចប្រជុំ បានថ្លែងអំណរគុណដល់សមាជិកក្រុមការងារលេខាធិការ ដែលបានចូលរួមប្រជុំនាពេលនេះ ព្រមទាំងពិនិត្យពិភាក្សាលំអិតលើរបៀបវារៈនីមួយៗដែលបានគ្រោងទុក ដោយសម្រេចលទ្ធផលដូចខាងក្រោម៖

១. បញ្ចប់ពិនិត្យលើពង្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៥ នៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍:

សមាជិកក្រុមការងារបានពិនិត្យ និងកែសម្រួលសម្រេចលើរបាយការណ៍ប្រចាំឆ្នាំ២០១៥ និងដាក់ជូនប្រធានក្រុមការងារពិនិត្យ និងសម្រេច។

២. ការកែសម្រួលសមាជិកភាពនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដោយសម្រេចដូចខាងក្រោម:

១.ការបង្កើតក្រុមប្រឹក្សាភិបាលនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

២. រក្សាសមាជិកភាពនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ និងក្រុមការងារលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ មានភ្ជាប់ពង្រាងសេចក្តីសម្រេចនៅខាងក្រោយ។

៣. ពិនិត្យលើអនុសាសន៍នៃកិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដោយសម្រេចដូចខាងក្រោម:

៣.១ អនុសាសន៍ខ្លះជាការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ និងខ្លះជាការទទួលរបស់អង្គការដែលអនុវត្តផ្ទាល់នៅសហគមន៍។

៣.២ ការប្រមូលរបាយការណ៍ប្រចាំត្រីមាសលើការងារបុរសស្រឡាញ់បុរស និងស្រីស្រស់ អង្គការ MHC ជាអ្នកទទួលភារៈកិច្ចប្រមូល។

៣.៣ រាល់ការធ្វើបទបង្ហាញក្នុងកិច្ចប្រជុំនានារបស់ក្រុមការងារ អង្គការរ៉ាក់(RHAC) មានភារៈកិច្ចសម្របសម្រួល និងត្រួតពិនិត្យលើអក្ខរាវិរុទ្ធឲ្យបានត្រឹមត្រូវមុននឹងធ្វើបទបង្ហាញ។

៣.៤ ក្នុងកិច្ចប្រជុំនានារបស់ក្រុមការងារ អង្គការ FHI360 មានភារៈកិច្ចសម្របសម្រួល និងធ្វើពិធីការក្នុងកិច្ចប្រជុំ។

**៥-សំណូមពរ និងអនុសាសន៍**

១. ស្នើរសមាជិកលេខាធិការដ្ឋានបំពេញតួនាទី និងភារៈកិច្ច ដែលបានឯកភាពគ្នាក្នុងកិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦។

២. ស្នើរសមាជិកលេខាធិការដ្ឋាន សូមបរិច្ចាកពេលវេលា ដើម្បីចូលរួមប្រជុំក្រុមការងារលេខាធិការដ្ឋាន ក៏ដូចក្រុមការងារបច្ចេកទេសឲ្យបានទៀងទាត់ និងគ្រប់ៗគ្នា។

៣. កិច្ចប្រជុំលើកក្រោយ ស្នើរបណ្តាញចតុមុខ បង្ហាញពីផែនការសកម្មភាពរបស់ខ្លួនដល់ក្រុមការងារ។

៤. ស្នើរសមាជិកលេខាធិការដ្ឋាន ជួយពង្រឹងបណ្តាញចតុមុខ នៅពេលមានការគាំទ្រថវិកាពីអង្គការខាណា(KHANA) ក្នុងការអនុវត្តសកម្មភាព។

## ៦-ការងារដែលត្រូវធ្វើបន្ត

១.ក្រុមការងារលេខាធិការដ្ឋាន នឹងរៀបចំកិច្ចប្រជុំប្រចាំខែមិថុនា ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦។

២.រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅបំណាច់ខែមិថុនា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ។

៣. រៀបចំឯកសាររបាយការណ៍ និងសេចក្តីសម្រេចរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច។

ភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦

| បានឃើញ និងឯកភាព | បានឃើញ និងពិនិត្យត្រឹមត្រូវ | អ្នកធ្វើរបាយការណ៍ |
| --- | --- | --- |
| អគ្គលេខាធិការ | ប្រធាននាយកដ្ឋាន | |